ការជួបជជែកគ្នារវាងតាតាបីនាក់ គឺ តាចិញ្ចក់ តាថ្មភ្នំ និងតាកង្កែប

តាចិញ្ចក់ថ្ងូរឡើងមុនគេថា : *ដោយភិក្ខុវោទានោ ស.សុភ័ណ*

**ខ្មែរអើយ ! អើយខ្មែរ !!**

ខ្មែរអើយ អើយខ្មែរ ទុក្ខសោកឥតល្ហែរ ព្រោះតែសង្គ្រាម
កាប់ចាក់គ្នាឯង ល្បែងបង្ហូរឈាម ឆ្អឹងសាច់ខ្លួនប្រាណ
ស្លាប់អសារបង់ ។

ខ្មែរអើយ អើយខ្មែរ ទួញយំឥតល្ហែរ ទុក្ខឥតបង្អង់
ម្ដាយប្រពន្ធកូន ព្រាត់ប្រាសលិចលង់ រស់ក្នុងអន្លង់
ក្ដីទុក្ខវេទនា ។

ខ្មែរអើយ អើយខ្មែរ ២០ ឆ្នាំប្លាយដែរ ខ្មែរគ្រប់អាត្មា
បានភ្លក់រស់ជាតិ ជូរចត់អស្ចារ្យ យល់ច្បាស់លោកា
ទមិឡអន្យត្រីយ៍ ។

រួចតាថ្មភ្នំបន្ថែមដោយមានមោទនភាពចំពោះខ្មែរថា :

ខ្មែរអើយ អើយខ្មែរ តើអ្នកដឹងទេ ? ខ្មែរពូជអ្នកថ្លៃ
អ្នកមានវប្បធម៌ រុងរឿងពេកក្រៃ នៅលើផែនដី
ក្រុងមហានគរ ។

ខ្មែរអើយ អើយខ្មែរ តើអ្នកឃើញទេ ? ប្រាង្គប្រាសាទថ្ម
ឈរខ្ពស់ត្រដែត ញញឹមសាទរ កល់ជាជំហរ
ទ្រព្រលឹងខ្មែរ ។

ខ្មែរអើយ អើយខ្មែរ តើអ្នកយល់ទេ ? ពូជពាក្យថាខ្មែរ
ជាពូជអ្នកថ្កើង បុរាណឪម៉ែ ជាអ្នកពូកែ
សាងមរតកលោក ។

ខ្មែរអើយ អើយខ្មែរ ត្រូវជួយគ្នាថែរ គ្រាប់ពូជនាំជោគ
បណ្ដុះសន្តិភាព ធម៌ស្ងប់ក្នុងលោក បំបាត់ទុក្ខសោក
ព្រោះធម៌សាមគ្គី ។

ខ្មែរអើយ  អើយខ្មែរ    ចូរព្រួតដៃគ្នា    តែមួយគ្មានពីរ
កាយ  វាចា  ចិត្ត    ត្បិតទាំងជីវី    បូជាពលី
មូលមិត្តករុណា ។

ខ្មែរអើយ  អើយខ្មែរ    កាយនោះត្រូវតែ    ធ្វើដោយមេត្តា
ទាំងពាក្យសំដី    ចិត្តគំនិតអាត្មា    ត្រូវមានមេត្តា
ឈ្មោះថាសាមគ្គី ។

ខ្មែរអើយ  អើយខ្មែរ    គឺអ្នកត្រូវតែ    ផ្គូរផ្គាប់ជីវី
ស្រលាញ់គ្នាឯង    ស្អិតដូចប្រថពី    ទើបខ្មែរនៅទី
គេកោតសរសើរ ។

ឯតាកង្កែបដែលធ្លាប់មានបទពិសោធន៍រស់នៅឯបរទេសក៏លើកឡើងថា :

ខ្មែរអើយ  អើយខ្មែរ    ឈ្លោះគ្នាឥតល្ហែរ    ខ្មែរនៅក្នុងស្រុក
ទោះខ្មែរឯនាយ    ឆ្ងាយចាកសំបុក    មិននៅជាសុខ
នៅបៀតបៀនគ្នា ។

ខ្មែរអើយ  អើយខ្មែរ    នៅមិនខ្មាស់គេ    នានាប្រជា
នៅឯនាយអាយ    ជាតិសាសន៍នានា    គេស្រលាញ់គ្នា
សាមគ្គីស្ងប់ស្ងៀម ។

ខ្មែរអើយ  អើយខ្មែរ    ទុក្ខអ្វីម្លេះទេ    មុខស្វិតក្រំក្រៀម
ប្រកាន់ខ្លួនប្រាណ    រស់ដូចអត់ឃ្លាន    ដូចគ្មានសីលទាន
ឈ្លោះទាស់ទែងគ្នា ។

ខ្មែរអើយ  អើយខ្មែរ    តើអ្នកឃើញទេ    កម្មពៀរវេរា
ព្រោះឈ្លោះគ្នាឯង    បរទេសគេពារ    រឹបស្រែចំការ
សល់ដីមួយក្តាប់ ។

តាថ្មភ្នំបញ្ចប់គាថាជាចុងក្រោយថា :

ខ្មែរអើយ  អើយខ្មែរ    អ្នកកុំគេចកែ    កុំអួតចំណាប់
ក្រោកឡើងសាមគ្គី    ក្តាប់ដៃអោយជាប់    រឹងមាំស្វាហាប់
ដូចថ្មអង្គរ ។

ភិក្ខុសេង  សុភ័ណ